# គោលការណ៍
# ណែនាំស្ដីពីសមាជិកភាព
# សហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់)

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RUCK

RAINBOW COMMUNITY KAMPUCHEA
ORGANISATION

សហគមន៍ឥន្ទធនូកម្ពុជាហៅកាត់ថា (រ៉ក់) ជាអង្គការអ្នកស្រឡាញ់ភេទដូចគ្នាដំបូងបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចុះបញ្ជីនិងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ២០៨ សជណ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ និងបានធ្វើបច្ចុប្បន្នភាពតាមរយៈលិខិតលេខ ១៧០៨ សជណ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ១. ទស្សនវិស័យ

រ៉ក់មានទស្សនវិស័យ ដែលប្រទេសកម្ពុជាក្លាយទៅជាទីកន្លែងសម្រាប់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នារស់នៅក្នុងជីវិត ដែលពោរពេញទៅដោយការទទួលបាននូវការគោរព ការទទួលស្គាល់ និងសិទ្ធិមនុស្សពេញលេញ ហើយស្មើគ្នានៅគ្រប់ផ្នែកទាំងអស់នៃសង្គម ជាពិសេសគ្រួសារ សហគមន៍ និងអាជ្ញាធរ។ ពួកយើងសង្ឃឹមថាប្រជាជនខ្មែរ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នាអាចសប្បាយចិត្តចំពោះខ្លួនឯង និងរស់នៅក្នុងជីវិតដ៏សប្បាយរីករាយ។ រ៉ក់គឺជាអង្គការរបស់អ្នកស្រឡាញ់ភេទដូចគ្នា ដែលមានឯករាជ្យភាព មិនពាក់ព័ន្ធ ឬបម្រើឱ្យនិន្នាការគណបក្សនយោបាយណាមួយឡើយ។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ២.គោលការណ៍ និងគុណតម្លៃរបស់រ៉ក់

ជាសមាជិក អ្នកត្រូវតែគោរពតាមគុណតម្លៃរបស់អង្គការសហគមន៍ឥន្ទធនូកម្ពុជាដូចតទៅ៖

- ពួកយើងគឺជាក្រុមដែលដឹកនាំដោយជនជាតិខ្មែរ ហើយធ្វើការឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ទាំងនៅទីប្រជុំជន និងតំបន់ជនបទ។
- ពួកយើងចែករំលែក តាមរយៈការចូលរួមតស៊ូមតិ ដើម្បីទាមទារឱ្យមានសមភាព និងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។
- ពួកយើងមានឆន្ទៈផ្ទាល់ខ្លួនក្នុងការចែករំលែកជំនាញ ចំណេះដឹង និងពេលវេលា ដែលធ្វើឱ្យការតស៊ូមតិកាន់តែមានភាពប្រសើរឡើង។
- ពួកយើងមានជំនឿលើភាពស្មើគ្នារបស់សមាជិករ៉ក់គ្រប់រូប ដែលគ្រប់គ្នាសុទ្ធតែមានតម្លៃ និងសំខាន់ដូចគ្នា ហើយការចូលរួមរបស់អ្នកទាំងអស់គ្នាជាតម្រូវការក្នុងការសម្រេចបានគោលដៅរួម។
- ពួកយើងគោរពសមាជិករ៉ក់គ្រប់គ្នា ទាំងក្មេង ឬចាស់ សមាជិកដែលមាន និងគ្មានបទពិសោធន៍ ទាំងអ្នកនៅទីក្រុង និងជនបទ។
- ពួកយើងគឺមានភាពស្មើគ្នាក្នុងការតស៊ូដើម្បីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។
- ពួកយើងបង្ហាញឱ្យសង្គមឃើញថា ពួកយើងគឺជាពលរដ្ឋដែលមានទំនួលខុសត្រូវដោយ៖
    - គោរពគ្រួសារ និងសហគមន៍របស់យើង
    - គោរពអាជ្ញាធរ ហើយយើងធ្វើការដោយមានសុជីវធម៌ និងការគោរព
    - ខំប្រឹងប្រែងធ្វើការក្នុងការបំពេញតួនាទីគ្រួសារ
    - មានចិត្តចង់រៀនសូត្រ និងអភិវឌ្ឍន៍ជំនាញនិងចំណេះដឹង
- ពួកយើងជឿជាក់ថា វិធីដែលល្អបំផុតក្នុងការបង្កើនការទទួលស្គាល់ពីក្រុមគ្រួសាររបស់ពួកយើង គឺពួកយើងត្រូវខិតខំប្រឹងប្រែងធ្វើការក្នុងការជួយ និងផ្តត់ផ្គង់ពួកគាត់ដើម្បីបង្ហាញថា ពួកយើងជាកូនដ៏ប្រពៃ។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ៣.ផលប្រយោជន៍នៃសមាជិកភាពរបស់រ៉ក់

- មានឱកាសពិភាក្សាពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា និងតម្រូវការពាក់ព័ន្ធនឹងអ្នកស្រឡាញ់ភេទដូចគ្នា។
- ទទួលបានឱកាសរៀនសូត្រ និងពង្រឹងសមត្ថភាពតាមរយៈវគ្គសិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចពិភាក្សានៅក្នុងវិទ្យុ និងសន្និបាតនៅក្នុងស្រុក និងក្រៅប្រទេស។
- មានអាទិភាព និងឱកាសទទួលបានការគាំទ្រ និងការការពារក្នុងករណីជួបប្រទះនឹងការរំលោភបំពានសិទ្ធិផ្សេងៗ។
- មានឱកាសកសាងទំនាក់ទំនង និងបណ្តាញជាមួយបងប្អូនដែលស្រឡាញ់ភេទដូចគ្នានៅទូទាំង២៥ខេត្តក្រុង រាជធានី ថ្នាក់តំបន់ និងពិភពលោក។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RUCK

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ៤.លក្ខណៈវិនិច្ឆ័យ

- ជាអ្នកស្រឡាញ់ភេទដូចគ្នា (ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អ្នកប្តូរភេទ និងអន្តរភេទ) នៅក្នុងដំណើរការចេញមុខជាចំហរ ឬ បានចេញមុខជាចំហររួចហើយ។
- ជឿជាក់និងគោរពសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។
- មានភាពស្មោះត្រង់ គោរពនិងឲ្យតម្លៃ ហើយផ្តល់ឱកាសដល់គ្នាទៅវិញទៅមក
- មានឆន្ទៈជួយចងក្រងសមាជិកថ្មីបន្ថែម និងរក្សាទំនាក់ទំនងល្អជាមួយសមាជិកចាស់។
- ចេះជួយទុក្ខធុរៈ និងគាំទ្រគ្នាទៅវិញទៅមកហើយមិនបោះបង់ចោលគ្នាពេលជួបបញ្ហា។
- មានការប្តេជ្ញាចិត្តក្នុងការលះបង់ពេលវេលា កំលាំងកាយ ចិត្ត និងស្មារតីក្នុងការចូលរួមរៀនសូត្រពង្រឹងសមត្ថភាព និងតស៊ូមតិដើម្បីឲ្យមានការគោរព និងការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាពេញលេញ។
- មានក្រមសីលធម៌រក្សាការសម្ងាត់នូវព័ត៌មានផ្ទៃក្នុងរបស់រ៉ក់ និងភាពឯកជនរបស់សមាជិកដទៃ។
- ជាពលរដ្ឋល្អនៅក្នុងសង្គម ក្លាហាន សកម្ម និងមានទំនួលខុសត្រូវ។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

ROCK

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ៥.តួនាទី និងការទទួលខុសត្រូវរបស់សមាជិករ៉ក់

- យល់ដឹងព័ត៌មានច្បាស់លាស់អំពីរ៉ក់។
- ចូលរួមនៅក្នុងដំណើរការពិភាក្សារៀបចំផែនការ យុទ្ធសាស្ត្រ ការងាររបស់រ៉ក់
- ទំនាក់ទំនងជាមួយអាជ្ញាធរ ឪពុកម្តាយ និងអាណាព្យាបាលរបស់អ្នកស្រឡាញ់ភេទដូចគ្នា។
- ចងក្រង ទំនាក់ទំនង ស្វែងយល់អំពីបញ្ហា និងគាំទ្រសមាជិកដទៃតាមរយៈការស្វែងរកដំណោះស្រាយទៅតាមលទ្ធភាព។
- ចែករំលែកព័ត៌មាននៃបញ្ហា តម្រូវការអាទិភាព និងលទ្ធផលសម្រេចបានល្អៗរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាទៅដល់ក្រុមការងាររ៉ក់តាមមូលដ្ឋាន។
- ផ្សព្វផ្សាយព័ត៌មានអំពីរ៉ក់ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាជាមួយ អ្នកស្រឡាញ់ភេទដូចគ្នាដែលជាសមាជិកថ្មី ចាស់ ឪពុកម្តាយ អាណាព្យាបាល  និងអាជ្ញាធរ ដើម្បីឱ្យមានការយល់ដឹង និងមានការគាំទ្រ។
- ចូលរួមសកម្មភាពផ្សេងៗរបស់រ៉ក់ រួមមាន សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការប្រជុំព្រឹត្តិការណ៍ប្រចាំឆ្នាំដូចជា សប្តាហ៍មោទនភាព ទិវាសិទ្ធិមនុស្ស សមាជរ៉ក់ (ប្រជុំសមាជិករ៉ក់ប្រចាំឆ្នាំ) ព្រមទាំងការតស៊ូមតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ជាដើម។

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ៦.លក្ខខណ្ឌសម្រាប់សមាជិករ៉ក់

- គោរពគុណតម្លៃ និងគោលការណ៍របស់រ៉ក់។
- មានភាពស្មោះត្រង់ តម្លាភាព និងការទទួលខុសត្រូវ។
- ជាបុគ្គលស្អាតស្អំ មិនប្រព្រឹត្តិអំពើពុករលួយ កេងបន្លំ កឹបកេង និងមិនប្រកាន់បក្សពួក។
- មានឆន្ទៈខ្ពស់ លះបង់ធនធានផ្ទាល់ខ្លួន ពេលវេលាដើម្បីចូលរួមសកម្មភាពនៅក្នុងកិច្ចការងាររ៉ក់ និងសាមគ្គីភាពក្នុងក្រុម។
- ជាមនុស្សល្អ និងពលរដ្ឋល្អប្រកបដោយសេចក្តីថ្លៃថ្នូរ។
- គោរពសិទ្ធិអ្នកដទៃ និងគោរពភាពចម្រុះគ្នា ភេទ យេនឌ័រ  ចំណេះដឹង កម្រិតអប់រំ បទពិសោធន៍ការងារ-ជីវិត អាយុ ជីវភាព-សេដ្ឋកិច្ច និងមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ឋានៈសង្គម វណ្ណៈ  ជំនឿ និងសាសនា។
- មានក្រមសីលធម៌ដោយគោរពភាពឯកជនរបស់បុគ្គល។
- គោរពព្រះមហាក្សត្រ។